# សង្ខេបគោលនយោបាយ៖ ការដោះស្រាយបន្ទុក និងផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃ NCDs ក្នុងចំណោមកុមារ និងយុវជននៅអាស៊ីអាគ្នេយ៍៖ វឌ្ឍនភាព បញ្ហាប្រឈម និងជម្រើសគោលនយោបាយសម្រាប់សភា AIPA

អ្នកស្រាវជ្រាវ៖ សូ សុវណ្ណរិទ្ធ

© 2024 Parliamentary Centre of Asia (PCAsia)

មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) គឺជាស្ថាប័នគាំទ្រសភាឯករាជ្យសម្រាប់សភាអាស៊ាន ដែលតបតាមសំណើររបស់សមាជិកសភា និងគណៈកម្មការសភា ដើម្បីផ្តល់ជូននូវឯកាសារបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវ និងការបណ្តុះបណ្តាលលើបញ្ហាបឬប្រធានបទសំខាន់ៗ ដែលទាក់ទងនឹងច្បាប់ និងគោលនយោបាយនាន នាពេលបច្ចុប្បន្ន។ របាយការណ៍នេះផ្តល់ព័ត៌មានជាទស្សនៈទាន ដែលពាក់ព័ន្ធនឹងការងារសភា ប៉ុន្តែមិនតំណាង ឬឆ្លុះបញ្ជាំងពីទស្សនៈរបស់មជ្ឈមណ្ឌលសភាអាស៊ី និងសភា និងសមាជិករបស់ខ្លួននៅក្នុងតំបន់។

ខ្លឹមសារនៃរបាយការណ៍បោះពុម្ពនេះគឺសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ដោយមិនមានបំណងផ្តល់ដំបូន្មានផ្នែកច្បាប់ ឬគោលនយោបាយ និងមិនបានដោះស្រាយរាល់បញ្ហាដែលគួរពិចារណានោះទេ។

ការអនុញ្ញាតឱ្យផលិតឡើងវិញទាំងស្រុង ឬមួយផ្នែក ឬប្រើប្រាស់ខ្លឹមសារនៅលើគេហទំព័រនេះអាចត្រូវបានស្វែងរកពីប្រភពឯកសារយោងនៅចុងបញ្ចប់នៃរបាយការណ៍នេះ។

## សង្ខេប

ជំងឺមិនឆ្លង រួមទាំងជំងឺធាត់ ជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម និងជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ កំពុងជះឥទ្ធិពលកាន់តែខ្លាំងឡើងលើកុមារ និងយុវជននៅអាស៊ីអាគ្នេយ៍។ ជំងឺមិនឆ្លង ទាំងនេះមិនត្រឹមតែបង្ហាញពីបញ្ហាប្រឈមសុខភាពសាធារណៈធ្ងន់ធ្ងរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់បន្ទុកសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរផងដែរ ដូចជាបង្កើនតំរូវការលើសលប់ចំពោះប្រព័ន្ធថែទាំសុខភាព ការបង្កើនអត្រាភាពក្រីក្រ និងការកាត់បន្ថយផលិតភាព។ អត្ថបទសង្ខេបនេះពិនិត្យលើផលប៉ះពាល់នៃ ជំងឺមិនឆ្លង លើកុមារ និងយុវជនក្នុងតំបន់ វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនៅទូទាំងប្រទេស និងបង្ហាញពីតួនាទីរបស់សភា AIPA ក្នុងការពន្លឿនសកម្មភាពគោលនយោបាយ។ ប្រទេសដូចជាសិង្ហបុរីបានបោះជំហានយ៉ាងសំខាន់ក្នុងការគ្រប់គ្រងជំងឺមិនឆ្លង រីឯប្រទេសមួយចំនួនទៀត រួមទាំងកម្ពុជា និងឡាវ មានវឌ្ឍនភាពយឺតនៃការអនុវត្តគោលនយោបាយ ។ សភា AIPA មានសារសំខាន់ក្នុងការជំរុញកំណែទម្រង់នីតិបញ្ញត្តិ ធានានូវការបែងចែកធនធានគ្រប់គ្រាន់ និងជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីដោះស្រាយវិបត្តិដែលកំពុងកើនឡើងនេះ។

## សេចក្តីផ្តើម

ជំងឺមិនឆ្លង គឺជាបុព្វហេតុឈានមុខនៃការស្លាប់ និងពិការភាពនៅទូទាំងពិភពលោក រីឯអាស៊ីអាគ្នេយ៍ក៏មមានការកើនឡើងគួរឲ្យព្រួយបារម្ភ ជាពិសេសក្នុងចំណោមកុមារ និងយុវជន។ ជំងឺមិនឆ្លង មានចំនួនច្រើនជាង 74% នៃការស្លាប់នៅក្នុងតំបន់ក្នុងឆ្នាំ 2021[1] ។ អត្រាមរណៈពីជម្ងឺមិនឆ្លង ប្រហែលពាក់កណ្តាលស្ថិតនៅក្រុមអាយុពី 30 ទៅ 69 ឆ្នាំនៅឆ្នាំ 2021[2]។ នេះគឺជាប្រភពចំណូលដ៏សំខាន់សម្រាប់គ្រួសារ និងសេដ្ឋកិច្ចជាតិ ហើយអាចរារាំងតំបន់នេះមិនឱ្យក្លាយជាសេដ្ឋកិច្ចធំជាងគេទីបួនរបស់ពិភពលោកនៅឆ្នាំ 2030។

កត្តាដែលរួមចំណែករួមមាន នគរូបនីយកម្មលឿន របបអាហារមិនល្អ និងរបៀបរស់នៅមិនមានសុខភាព។ ប្រសិនបើមិនបានត្រួតពិនិត្យ នោះ ជំងឺមិនឆ្លង នឹងបន្តធ្វើឱ្យសុខភាពសាធារណៈកាន់តែយ៉ាប់យ៉ឺន និងរារាំងដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ដូច្នេះ ការដោះស្រាយជម្ងឺមិនឆ្លង គឺជាកត្តាសំខាន់មិនត្រឹមតែធ្វើឱ្យលទ្ធផលសុខភាពប្រសើរឡើងប៉ុណ្ណោះទេ ថែមទាំងកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ។ សភា AIPA មានតួនាទីសំខាន់ក្នុងការបង្កើតគោលនយោបាយ

ប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាដែលនាំឱ្យមានជំងឺមិនឆ្លង និងកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចសង្គមរយៈពេលវែង។

## បន្ទុក និងផលប៉ះពាល់នៃ ជំងឺមិនឆ្លង លើកុមារ និងយុវជន

បន្ទុកនៃជំងឺមិនឆ្លង លើកុមារ និងយុវជននៅអាស៊ីអាគ្នេយ៍ មានច្រើនផ្នែក។ បន្ទុកផ្ទាល់រួមមានការបង្កើនថ្លៃថែទាំសុខភាព និងបង្កើនតម្រូវការពេទ្យជំនាញ ឬអ្នកឯកទេសផ្សេងនៃផ្នែកជំងឺមិនឆ្លង ខណៈពេលដែលបន្ទុកដោយប្រយោលប៉ះពាល់ដល់ផលិតភាព ការទទួលបានការអប់រំ និងការរើសអើងក្នុងសង្គម-ជាពិសេសទាក់ទងនឹងការធាត់ និងជំងឺរុំារ៉ៃ។ ភាពធាត់ក្នុងវ័យកុមារបានលេចចេញជាកត្តាហានិភ័យដ៏សំខាន់សម្រាប់ ជំងឺមិនឆ្លង ។ ប្រទេសដូចជាម៉ាឡេស៊ី ថៃ និងឥណ្ឌូណេស៊ី បានកំពុងកើនឡើងនៃអត្រាធាត់របស់កុមារ។ ជាង 30% នៃកុមារនៅអាស៊ីអាគ្នេយ៍ឥឡូវនេះត្រូវបានរងផលប៉ះពាល់ដោយការលើសទម្ងន់ ឬធាត់ ដែលធ្វើឲ្យពួកគេប្រឈមនឹងហានិភ័យខ្ពស់នៃការវិវត្តទៅជាជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមបេះដូង និងជំងឺមិនឆ្លង ផ្សេងទៀត [3]។

ផលប៉ះពាល់សេដ្ឋកិច្ចសង្គមមានទំហំធំណាស់។ ជំងឺមិនឆ្លង រួមចំណែកដល់ការកាត់បន្ថយឱកាសសិក្សា និងការងារ ដែលបណ្តាលឱ្យធ្លាក់ចូលវដ្តនៃភាពក្រីក្រ។ នៅក្នុងបណ្តាប្រទេសដូចជាកម្ពុជា និងឡាវ ដែលមានប្រព័ន្ធថែទាំសុខភាពទទួលបានថវិកាមានកំរឹត, ការចំណាយលើការព្យាបាលជម្ងឺមិនឆ្លង ការចំណាយពីហោប៉ៅខ្លួនឯងខ្ពស់លើសពី 50% នៃការចំណាយលើសុខភាព សម្រាប់កម្ពុជានិងមីយ៉ានម៉ា ធ្វើឱ្យវិសមភាពសង្គមដែលមានស្រាប់កាន់តែធ្ងន់ធ្ងរ [4]។

## វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ NCD

បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍បង្ហាញកម្រិតផ្សេងៗនៃវឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយ NCD៖

1. **វឌ្ឍនភាពនាំមុខគេ៖** ប្រទេសសិង្ហបុរីបានរីកចម្រើនយ៉ាងខ្លាំងក្នុងការដោះស្រាយជំងឺមិនឆ្លង ជាពិសេសក្នុងចំណោមកុមារ និងយុវជន។ យុទ្ធនាការ "ផែនការមេនៃការរស់នៅប្រកបដោយសុខភាពល្អ" និងយុទ្ធនាការ "សង្គ្រាមលើជំងឺទឹកនោមផ្អែម" សង្កត់ធ្ងន់លើការលើកកម្ពស់សុខភាព និងការអន្តរាគមន៍ដំបូងតាមរយៈកម្មវិធីនៅតាមសាលារៀន និងយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ។ វិធានការបទប្បញ្ញត្តិ ដូចជាការយកពន្ធលើភេសជ្ជៈផ្អែមមានជាតិស្ករ គឺជាឧបករណ៍មួយ

ក្នុងការធ្វើឱ្យមានស្ថេរភាពអត្រាធាត់របស់កុមារ និងកាត់បន្ថយជំងឺទឹកនោមផ្អែមដែលចាប់ផ្តើមដំបូង [5] ។

2. **វឌ្ឍនភាពកម្រិតមធ្យម៖** ប្រទេសថៃមានការរីកចម្រើនមធ្យមក្នុងការដោះស្រាយជំងឺមិនឆ្លងក្នុងចំណោមកុមារ និងយុវជន តាមរយៈផែនការបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លងជាតិរបស់ខ្លួន។ ប្រព័ន្ធថែទាំសុខភាពជាសាកលរបស់ប្រទេសបានផ្តល់លទ្ធភាពកាន់តែទូលំទូលាយដល់ការថែទាំបង្ការ និងព្យាបាលសម្រាប់ជំងឺមិនឆ្លង។ កម្មវិធីនៅតាមសាលាដែលមានបំណងកែលម្អអាហារូបត្ថម្ភ និងការលើកកម្ពស់សកម្មភាពរាងកាយក៏ត្រូវបានអនុវត្តផងដែរ ដើម្បីដោះស្រាយភាពធាត់របស់កុមារ។ ទោះបីជាមានគំនិតផ្តួចផ្តើមទាំងនេះក៏ដោយ នគរូបនីយកម្ម និងការកើនឡើងប្រជាប្រិយភាពនៃអាហារកែច្នៃបាននាំឱ្យមានការកើនឡើងនៃភាពធាត់របស់កុមារ ជាពិសេសនៅក្នុងតំបន់ទីក្រុង។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលថៃ រួមទាំងការលើកកម្ពស់ការជ្រើសរើសអាហារដែលមានសុខភាពល្អ និងលើកកម្ពស់ការអប់រំកាយ បានទទួលជោគជ័យខ្លះៗ ប៉ុន្តែនៅមានកម្រិត ជាពិសេសនៅតាមតំបន់ជនបទ ដែលហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពនៅមិនទាន់អភិវឌ្ឍដូចតំបន់ទីក្រុងនៅឡើយ។ ការពង្រឹងយុទ្ធនាការសុខភាពសាធារណៈ និងការពង្រឹងការសម្របសម្រួលអន្តរវិស័យអាចជំរុញកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសថៃបន្ថែមទៀតក្នុងការគ្រប់គ្រងជំងឺមិនឆ្លង [6]។

3. **វឌ្ឍនភាពយឺត៖** កម្ពុជា និងឡាវមានការវិវត្តន៍យឺតក្នុងឆ្លើយតបទៅនឹងតម្រូវការដោះស្រាយជំងឺមិនឆ្លងក្នុងចំណោមកុមារ និងយុវជន។ ប្រទេសទាំងពីរនេះប្រឈមមុខនឹងបញ្ហាដូចជាហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពនៅមានកម្រិត ធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ និងកង្វះការប្តេជ្ញាចិត្តចំពោះគោលនយោបាយទប់ស្កាត់ជំងឺ NCD ជាតិ។ ខណៈពេលដែលគោលនយោបាយមួយចំនួនដែលផ្តោតលើការកែលម្អលទ្ធភាពទទួលបានការថែទាំសុខភាពត្រូវបានណែនាំ ប៉ុន្តែសេវាទាំងនោះនៅតែមិនទាន់គ្រប់គ្រាន់។ ប្រព័ន្ធថែទាំសុខភាពរបស់កម្ពុជា ខ្វះថវិកា ហើយការយល់ដឹងជាសាធារណៈអំពីហានិភ័យ NCD មានកម្រិតទាប។ ដូចគ្នានេះដែរ ប្រទេសឡាវជួបការលំបាកជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពមិនល្អ និងខ្វះការអនុវត្តបទប្បញ្ញត្តិស្តីពីការផ្សាយពាណិជ្ជកម្មអាហារមិនល្អ។ ការពង្រឹងប្រព័ន្ធថែទាំសុខភាព និងការបង្កើនមូលនិធិសុខភាពសាធារណៈគឺចាំបាច់សម្រាប់វឌ្ឍនភាពប្រកបដោយអត្ថន័យ [3, 4,7].

## តួនាទីរបស់សភា AIPA ក្នុងការទប់ស្កាត់ និងត្រួតពិនិត្យជំងឺមិនឆ្លង

សភា AIPA មានតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺមិនឆ្លងតាមរយៈសកម្មភាពនីតិបញ្ញត្តិ ការបែងចែកធនធាន និងកិច្ចសហការក្នុងតំបន់។

1. AIPA អាចពនិត្យច្បាប់ឡើងវិញដើម្បីធានាបង្កើតបរិយាកាសសុខភាពសម្រាប់កុមារ និងយុវជន។ នេះរួមបញ្ចូលទាំងការធ្វើនិយតកម្មទីផ្សារនៃអាហារដែលមិនមានសុខភាព ការយកពន្ធលើភេសជ្ជៈមានជាតិស្ករ និងការបង្ខំឱ្យមានការអប់រំកាយនៅក្នុងសាលារៀន។ "សង្គ្រាមលើជំងឺទឹកនោមផ្អែម" របស់ប្រទេសសិង្ហបុរីផ្តល់នូវគំរូមួយសម្រាប់របៀបដែលច្បាប់អាចកំណត់កត្តាហានិភ័យនៅដំណាក់កាលដំបូង។

2. សភាមានទួនាទីធានាអាទិភាពដល់ការទប់ស្កាត់ជំងឺមិនឆ្លងក្នុងថវិកាជាតិ។ សមាជិក AIPA អាចតស៊ូមតិសម្រាប់ការបង្កើនមូលនិធិសម្រាប់យុទ្ធនាការសុខភាពសាធារណៈ អន្តរាគមន៍នៅតាមសាលារៀន និងសេវាថែទាំសុខភាព និង ប្រព័ន្ធត្រួតពិនិត្យជំងឺមិនឆ្លង ។ តំបន់ជនបទ និងតំបន់ដែលមិនទាន់មានសេវាគ្រប់គ្រាន់ត្រូវការការយកចិត្តទុកដាក់ជាពិសេស ដោយសារតំបន់ទាំងនេះតែងតែជួបប្រទះនូវអត្រាប្រេវ៉ាឡង់ជំងឺមិនឆ្លង ខ្ពស់ជាងមុន ដោយសារលទ្ធភាពទទួលបានសេវាថែទាំសុខភាពមានកម្រិត។

3. ការទប់ស្កាត់ និងគ្រប់គ្រងជំងឺមិនឆ្លង ទាមទារអោយមានការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងក្នុងតំបន់។ សភា AIPA អាចជួយសម្រួលដល់ការចែករំលែកចំណេះដឹង ការប្រមូលផ្តុំធនធាន និងការកសាងសមត្ថភាពនៅទូទាំងអាស៊ីអាគ្នេយ៍។ ប្រទេសដូចជាប្រទេសសិង្ហបុរី ដែលបានកាត់បន្ថយអត្រាជំងឺ NCD ដោយជោគជ័យ អាចគាំទ្របច្ចេកទេសដល់ ប្រទេសដែលមានចំណូលទាប ដូចជាកម្ពុជា និងឡាវ ក្នុងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព។

## ជម្រើសគោលនយោបាយសម្រាប់សភា AIPA

ដើម្បីដោះស្រាយបន្ទុកដែលកំពុងកើនឡើងនៃ ជំងឺមិនឆ្លង ក្នុងចំណោមកុមារ និងយុវជន សភា AIPA គួរតែពិចារណាវិធានការគោលនយោបាយមួចំនួនខាងក្រោមនេះ៖

1. ណែនាំបទប្បញ្ញត្តិដើម្បីដាក់កម្រិតលើទីផ្សារនៃអាហារដែលមិនមានសុខភាព ការដាក់ពន្ធលើភេសជ្ជៈមានជាតិស្ករ និងកំណត់អាណត្តិការអប់រំសុខភាពដ៏ទូលំទូលាយនៅក្នុងសាលារៀន។

2. ចាប់ផ្តើមគំនិតផ្តួចផ្តើមសុខភាពសាធារណៈក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីរបប អាហារដែលមានសុខភាពល្អ សកម្មភាពរាងកាយទៀងទាត់ និងការបង្ការជំងឺមិនឆ្លង ដំណាក់កាល ដំបូង ជាពិសេសផ្តោតលើកុមារដែលមានអាយុចូលរៀន។
3. ពង្រីកសេវាថែទាំសុខភាពបង្ការ ជាពិសេសនៅតំបន់ជនបទ និងតំបន់ដែលខ្វះខាត ដើម្បីកាត់ បន្ថយកត្តាហានិភ័យ ជំងឺមិនឆ្លង ក្នុងចំណោមប្រជាជនដែលងាយរងគ្រោះ។
4. កៀរគរធនធានដើម្បីសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល និងធ្វើការស្ទង់មតិប្រជាជន ដើម្បីតាមដានវឌ្ឍនភាពនៃសេវាសុខភាពដែលទាក់ទងនឹងជំងឺមិនឆ្លង បន្ទាប់ពីការអនុវត្តការស្ទង់ មតិលើហានិភ័យសុខភាព។
5. លើកកម្ពស់កិច្ចសហប្រតិបត្តិការឆ្លងដែន និងចែករំលែកឧត្តមានុវត្តន៍ ដើម្បីបង្កើនយុទ្ធសាស្រ្តបង្ការ ជំងឺមិនឆ្លង នៅទូទាំងអាស៊ីអាគ្នេយ៍។

## សេចក្តីសន្និដ្ឋាន

ការកើនឡើងអត្រាប្រេវ៉ាឡង់នៃជំងឺមិនឆ្លង ក្នុងចំណោមកុមារ និងយុវជននៅអាស៊ីអាគ្នេយ៍ បង្ហាញពី ការគំរាមកំហែងយ៉ាងសំខាន់ដល់សុខភាពសាធារណៈ និងស្ថិរភាពសេដ្ឋកិច្ចសង្គម។ ខណៈពេលដែល ប្រទេសដូចជាប្រទេសសិង្ហបុរីមានការរីកចម្រើនគួរឱ្យកត់សម្គាល់នោះ ប្រទេសមួយចំនួនទៀត រួមទាំង កម្ពុជា និងឡាវ ប្រឈមមុខនឹងបញ្ហាជាច្រើនផងដែរ។ សភា AIPA មានទីភារៈកិច្ចពិសេសដើម្បីធានា អោយមានដំណោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈសកម្មភាពនីតិប្បញ្ញត្តិ ការបង្កើនការបែង ចែកធនធាន និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់។ តាមរយៈការអនុវត្តវិធានការគោល នយោបាយដែលបានណែនាំ សភា AIPA អាចបង្កើតបរិយាកាសដែលមានសុខភាពល្អជាងមុនសម្រាប់ កុមារ និងយុវជន ដែលទីបំផុតរួមចំណែកដល់អនាគតដ៏ត្រចះត្រចង់ និងនិរន្តរភាពសម្រាប់តំបន់។

---

[1] World Health Organization (2022). NCD Country Profiles. Available at https://www.who.int/teams/noncommunicable-diseases/surveillance/data/profiles-ncd Accessed on May 9, 2024

[2] World Health Organization. Non-communicable diseases. WHO South-East Asia (2022). WHO South-East Asia Region to accelerate progress for NCD prevention and control, available at https://www.who.int/southeastasia/news/detail/07-09-2022-who-south-east-asia-region-to-accelerate-progress-for-ncd-prevention-and-control, Accessed July 10, 2024

[3] Unicef and Asean (2024). Minimum standards and guidelines on actions to protect children from the harmful impact of marketing of food and non-alcoholic beverages in the ASEAN

region. Available at https://asean.org/wp-content/uploads/2023/09/Digital_Single-pages_ASEAN-GMS_Marketing-to-children_FINAL_23Apr24.pdf. Assessed on June 2, 2024

[4] WHO South-East Asia (2022). *WHO South-East Asia Region to accelerate progress for NCD prevention and control*. Available at: https://www.who.int/southeastasia/news/detail/07-09-2022-who-south-east-asia-region-to-accelerate-progress-for-ncd-prevention-and-control [Accessed 10 July 2024].

[5] Singapore Ministry of Health (2014). The Healthy Living Master Plan. Available at https://extranet.who.int/countryplanningcycles/sites/default/files/planning_cycle_repository/singapore/moh_healthy_living_master_plan_inside_page_8d.pdf. Accessed on March 11, 2024

[6] United Nations Thailand (n.a) Prevention and Control of Noncommunicable Diseases in Thailand: Case for Investment. Available at https://www.undp.org/sites/g/files/zskgke326/files/migration/th/UNDP_TH_WHO_THAILAND_NCD-IC-REPORT_v06_231121.pdf.

4. Sornpaisarn, B., Limmade, Y., Pengpid, S., Jayasvasti, I., Chhoun, P., Somphet, V., Mustapha, F.I., Kaung, K.K., Chailek, C., Bao, T.Q. and Rehm, J., 2023. Assessing data availability of NCD prevention and control in six ASEAN countries based on WHO global monitoring framework and the progress monitor indicators. BMC Public Health, 23(1), p.272.